ការរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីរ

អែលឌើរ នែល អិល អាន់ឌើរសិន
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

បេសកកម្មរបស់អ្នកនឹងក្លាយជាឱកាសដ៏ពិសិដ្ឋមួយដើម្បីនាំអ្នកដទៃទៀតមកកាន់ព្រះគ្រីស្ទ និងជួយរៀបចំ « សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ » ។

យប់នេះ ខ្ញុំនិយាយជាពិសេសទៅកាន់ក្មួយៗ អាយុ 12 ដល់ 25 ឆ្នាំ ដែលកាន់បព្វជិតភាពរបស់ព្រះ ។ យើងគិតច្រើនអំពីអ្នក ហើយយើងអធិស្ឋានសម្រាប់អ្នក ។ មានម្តង ខ្ញុំបានប្រាប់រឿងរបស់ចៅប្រុសអាយុបួនឆ្នាំរបស់យើង ដែលបានរុញប្អូនប្រុសតូចរបស់គេយ៉ាងខ្លាំង ។ បន្ទាប់ពីបានលួងចៅដែលយំហើយ ប្រពន្ធរបស់ខ្ញុំ ខេធី បានងាកទៅឯចៅអាយុបួនឆ្នាំ ហើយបានសួរដោយការគិតគូរថា « ហេតុអ្វីចៅរុញប្អូន ? » ចៅប្រុសយើងបានមើលទៅលោកយាយរបស់គេ ហើយបានឆ្លើយតបថា « លោកយាយ ចៅសុំទោស ។ ចៅបាត់ចិញ្ចៀន ជ្រើសផ្លូវត្រូវ របស់ចៅ ហើយចៅមិនអាចជ្រើសធ្វើត្រូវបានទេ » ។ យើងដឹងថាអ្នកព្យាយាមយ៉ាងខ្លាំង ដើម្បីជ្រើសអ្វីដែលត្រូវជានិច្ច ។ យើងស្រឡាញ់អ្នកខ្លាំងណាស់ ។

តើអ្នកធ្លាប់គិតទេ ថាហេតុអ្វីអ្នកត្រូវបានបញ្ជូនមកផែនដីនៅពេលជាក់លាក់នេះ ? អ្នកមិនបានកើតមកកំឡុងពេលនៃអ័ដាម និងអេវ៉ាទេ ឬក៏នៅពេលដែលស្តេចជាវ៉ោន គ្រងប្រទេសអេហ្ស៊ីប ឬកំឡុងពេលរាជវង្ស មិង ដែរ ។ អ្នកបានមកផែនដីនៅពេលនេះ គឺសតវត្សទី 20 បន្ទាប់ពីការយាងមកលើកទីមួយរបស់ព្រះគ្រីស្ទ ។ បព្វជិតភាពនៃព្រះត្រូវបានស្តារឡើងដល់ផែនដីនេះ ហើយព្រះអម្ចាស់បានដាក់ព្រះហស្តរបស់ទ្រង់ ដើម្បីរៀបចំពិភពលោកនេះសម្រាប់ការយាងត្រឡប់ដ៏រុងរឿងរបស់ទ្រង់ ។ ពេលនេះជាឱកាសដ៏អស្ចារ្យ និងការទទួលខុសត្រូវដ៏សំខាន់ ។ ទាំងនេះគឺជាពេលវេលារបស់អ្នក ។

ជាមួយនឹងបុណ្យជ្រមុជទឹករបស់អ្នក អ្នកបានប្រកាសពីក្តីជំនឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទ ។ ជាមួយនឹងការតែងតាំងដល់បព្វជិតភាពរបស់អ្នក ទេពកោសល្យ និងសមត្ថភាពខាងវិញ្ញាណរបស់អ្នកបានបង្កើនឡើង ។ ការទទួលខុសត្រូវមួយដ៏សំខាន់របស់អ្នក គឺដើម្បីជួយរៀបចំពិភពលោកនេះសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

ព្រះអម្ចាស់បានតាំងព្យាការីមួយឡើង គឺប្រធាន ថូម៉ាស អេស ម៉នសុន ដើម្បីដឹកនាំកិច្ចការនៃបព្វជិតភាពទ្រង់ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍មកកាន់អ្នកថា « ព្រះអម្ចាស់ត្រូវការអ្នកផ្សព្វផ្សាយសាសនា » ។[1] « យុវជនគ្រប់រូបដែលមានភាពសក្តិសម និងមានសមត្ថ -ភាពគួរតែរៀបចំខ្លួនដើម្បីបម្រើបេសកកម្ម ។ ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា គឺជាកាតព្វកិច្ចរបស់បព្វជិតភាព---ជាកាតព្វកិច្ចដែលព្រះអម្ចាស់រំពឹងចង់បានពី [អ្នក] ដែលជាអ្នកដែលត្រូវបានប្រគល់ឲ្យនូវអ្វីៗជាច្រើន » ។[2]

ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាតម្រូវនូវការពលិកម្ម ។ នឹងតែងតែមានអ្វីមួយដែលអ្នកត្រូវទុកចោល នៅពេលដែលអ្នកឆ្លើយតបទៅនឹងការហៅរបស់ព្យាការីដើម្បីបម្រើ ។

អ្នកដែលតាមដានការប្រកួតបាល់អោប ស្គាល់ ក្រុមខ្មៅទាំងអស់របស់ នូហ្ស៊ីឡិន ដែលជាឈ្មោះដែលគេដាក់ឲ្យ ដោយសារតែពណ៌ឯកសណ្ឋានរបស់គេគឺជាក្រុមបាល់អោបដែលល្បីល្បាញជាងគេ ។[3] ដើម្បីត្រូវបានជ្រើសរើសឲ្យចូលក្នុងក្រុម « ខ្មៅទាំងអស់ » នៅ នូហ្ស៊ីឡិន នោះអ្នកត្រូវតែអាចធៀបទៅនឹងអ្នកលេងឲ្យក្រុមបាល់ឱប ឬក្រុមបាល់ទាត់ពិភពលោក ។

នៅឆ្នាំ 1961 ក្នុងអាយុ 18 ឆ្នាំ និងជាអ្នកកាន់បព្វជិតភាពអើរ៉ុន ស៊ីដនី ហ្គូអ៊ីង បានក្លាយជាតារាបាល់ឱបម្នាក់ក្នុងប្រទេស នូហ្ស៊ីឡិន ។ ព្រោះតែសមត្ថភាពដ៏គួរឲ្យកត់សម្គាល់របស់គាត់ មនុស្សជាច្រើនបានគិតថា គាត់នឹងត្រូវបានជ្រើសចូលក្នុងក្រុមបាល់អោបជម្រើសជាតិ « ខ្មៅទាំងអស់ » ។

នៅអាយុ 19 ឆ្នាំ ក្នុងគ្រាដ៏សំខាន់បំផុតនៃអាជីពបាល់អោបដែលកំពុងឡើងកូដរបស់គាត់នេះ ស៊ីដ បានប្រកាសថា គាត់នឹងលះបង់បាល់អោប ដើម្បីទៅបម្រើបេសកកម្មវិញ ។ អ្នកខ្លះបានហៅគាត់ថាជា « មនុស្សឆ្កួត » ។ អ្នកផ្សេងទៀតបានហៅគាត់ថាជា « មនុស្សភ្លើ » ។[4] ពួកគេបានជំទាស់ ដោយថាឱកាសនៅក្នុងបាល់អោបរបស់គាត់ នឹងមិនដែលមានម្តងទៀតទេ ។

សម្រាប់ ស៊ីដ វាមិនមែនជាអ្វីដែលគាត់ទុកចោលនោះទេ វាជាឱកាស និងជាការទទួលខុសត្រូវ ។ គាត់មានកាតព្វកិច្ចបព្វជិតភាព ដើម្បីផ្តល់ពេលពីរឆ្នាំក្នុងជីវិតគាត់ ដើម្បីប្រកាសពីការពិតនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលស្តារឡើងវិញរបស់ទ្រង់ ។ គ្មានអ្វី---ដែលធ្វើឲ្យគាត់រុញរាពីការបំពេញកាតព្វកិច្ចនោះទេ---សូម្បីតែឱកាសដើម្បីលេងក្នុងក្រុមជម្រើសជាតិ ជាមួយនឹងភាពល្បីល្បាញក៏ដោយ ។[5]

គាត់ត្រូវបានហៅដោយព្យាការីនៃព្រះ ឲ្យបម្រើក្នុងបេសកកម្ម កាណាដាខាងលិច ។ 48 ឆ្នាំកន្លងទៅហើយ នៅក្នុងខែនេះ អែលឌើរ ស៊ីដនី ហ្គូអ៊ីង អាយុ 19 ឆ្នាំ បានចាកចេញពីប្រទេស ន្យូហ្ស៊ីឡិន ដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាសម្រាប់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ស៊ីដ បានប្រាប់ខ្ញុំពីបទពិសោធន៍ដែលគាត់មានក្នុងបេសកកម្មរបស់គាត់ ។ នាពេលល្ងាចមួយ គាត់និងដៃគូ ជិតនឹងត្រឡប់ចូលផ្ទះទៅហើយ ។ ពួកគាត់បានសម្រេចចិត្តទៅជួបគ្រួសារមួយទៀត ។ ឪពុកបានឲ្យពួកគាត់ចូល ។ អែលឌើរ ហ្គូអ៊ីង និងដៃគូគាត់ថ្លែងទីបន្ទាល់ពីព្រះអង្គសង្គ្រោះ ។ គ្រួសារនោះបានទទួលយកព្រះគម្ពីរមរមន ។ ឪពុកបានអានអស់ពេញមួយយប់ ។ ក្នុងពេលតែមួយសប្តាហ៍កន្លះប៉ុណ្ណោះ គាត់បានអានចប់ទាំងអស់ ទាំងព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្តីសញ្ញា និងមុក្តាដ៏មានតម្លៃមហិមា ។ ពីរបីសប្តាហ៍ក្រោយមកគ្រួសារនោះបានទទួលបុណ្យជ្រមុជទឹក ។[6]

តើបេសកកម្មជំនួសឲ្យកន្លែងមួយក្នុងក្រុមខ្មៅទាំងអស់របស់ ន្យូហ្ស៊ីឡិន ឬ? ស៊ីដ បានឆ្លើយតបថា « ពរជ័យនៃ [ការនាំអ្នកដទៃ] មកកាន់ដំណឹងល្អ សំខាន់ជាងអ្វីៗទាំងអស់ដែល [អ្នក] លះបង់ » ។[7]

អ្នកប្រហែលជាឆ្ងល់ថា អ្វីបានកើតឡើងចំពោះ ស៊ីដ ហ្គូអ៊ីង បន្ទាប់ពីបេសកកម្ម ? អ្វីដែលសំខាន់បំផុតគឺ ៖ អាពាហ៍ពិពាហ៍ដ៏អស់កល្បជាមួយនឹងមនុស្សជាទីស្រឡាញ់របស់គាត់គឺ ខូលីន កូនៗដ៏ឧត្តមប្រាំនាក់ និងតំណចៅៗទៀត ។ គាត់បានរស់នៅដោយទុកចិត្តទៅលើព្រះវរបិតាសួគ៌របស់គាត់ រក្សាបទបញ្ញត្តិ និងបម្រើអ្នកដទៃ ។

ចុះបាល់ឱបវិញ ? បន្ទាប់ពីបេសកកម្ម ស៊ីដ ហ្គូអ៊ីង ក្លាយជាខ្សែការពារដ៏អស្ចារ្យម្នាក់ក្នុងប្រវត្តិក្រុម « ខ្មៅទាំងអស់ » ដោយលេងបាន 11 រដូវកាល និងបានបម្រើជាប្រធានក្រុមអស់រយៈពេលជាច្រើនឆ្នាំ ។[8]

តើ ស៊ីដ ហ្គូអ៊ីង លេងល្អយ៉ាងណាទៅ ? គាត់លេងល្អខ្លាំងណាស់ រហូតដល់ធ្វើឲ្យកាលវិភាគនៃការបង្វឹក និងការប្រកួតត្រូវផ្លាស់ប្តូរ ដោយសារគាត់នឹងមិនលេងនៅថ្ងៃអាទិត្យទេ ។[9] ស៊ីដ ល្អណាស់រហូតដល់ ព្រះម្ចាស់ក្សត្រីនៃប្រទេសអង់គ្លេសបានទទួលស្គាល់ពីការបូជារបស់គាត់ចំពោះបាល់អោប ។[10] គាត់ល្អខ្លាំងណាស់រហូតដល់ថ្នាក់មានគេសរសេរជាសៀវភៅមួយអំពីគាត់ដែលមានចំណងជើងថា « ស៊ីដ ដ៏អស្ចារ្យ » ។

ចុះបើ ស៊ីធ មិនបានទទួលកិត្តិយសទាំងនោះបន្ទាប់ពីបេសកកម្មរបស់គាត់វិញ ? អព្ភូតហេតុមួយដ៏អស្ចារ្យនៃការបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅក្នុងសាសនាចក្រគឺថា ស៊ីដ ហ្គូអ៊ីង និងជាច្រើនពាន់នាក់ទៀតដែលដូចជាគាត់ដែរ មិនបានសួរថា « តើខ្ញុំនឹងទទួលអ្វីពីបេសកកម្មរបស់ខ្ញុំ ? » ប៉ុន្តែសួរថា « តើអ្វីដែលខ្ញុំអាចផ្តល់ឲ្យ ? »

បេសកកម្មរបស់អ្នកនឹងជាឱកាសដ៏ពិសិដ្ឋមួយដើម្បីនាំអ្នកដទៃទៀតមកកាន់ព្រះគ្រីស្ទ និងជួយរៀបចំ « សម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ » ។ ព្រះអម្ចាស់បានមានព្រះបន្ទូលជាយូរណាស់មកហើយ ពីការរៀបចំដ៏ចាំបាច់ សម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ទ្រង់បានប្រកាសទៅកាន់ ហោណុក ថា « ហើយរីឯសេចក្តីសុចរិត នោះយើងនឹងចាត់ឲ្យចុះមកពីស្ថានសួគ៌ ហើយឯសេចក្តីពិត នោះយើងនឹងចាត់ឲ្យចេញពីផែនដីទៅ... ហើយសេចក្តីសុចរិត និងសេចក្តីពិតនោះយើងនឹងបណ្តាលឲ្យបោសផែនដី ដូចជាទឹកជំនន់ ដើម្បីប្រមូលពួកអ្នកជម្រើសរបស់យើង ពីទិសទាំងបួននៃផែនដី » ។[11] ព្យាការី ដានីយ៉ែល បានព្យាករណ៍ថា នៅក្នុងថ្ងៃចុងក្រោយ ដំណឹងល្អនឹងរមៀលចេញទៅដល់ចុងផែនដី ដូចជា « ថ្ម [ដែលត្រូវបាន] ដាប់ផ្តាច់ចេញពីភ្នំ [មួយ] ឥតមានដៃអ្នកណាធ្វើ » ។[12] នីហ្វៃបាននិយាយពីសាសនាចក្រនៃថ្ងៃចុងក្រោយថាមានចំនួនតិចតួច ប៉ុន្តែមាននៅពាសពេញផ្ទៃផែនដី ។[13] ព្រះអម្ចាស់បានប្រកាសនៅជំនាន់នេះថា « អ្នករាល់គ្នាត្រូវបានហៅមក ដើម្បីបណ្តាលឲ្យមានការប្រមូល នៃពួកដែលយើងបានរើសតាំង » ។[14] បងប្អូនប្រុសវ័យក្មេងរបស់ខ្ញុំអើយ បេសកកម្មរបស់អ្នកជាឱកាស និងការទទួលខុសត្រូវដ៏អស្ចារ្យ ដែលសំខាន់ដល់ការប្រមូលផ្តុំដែលបានសន្យានេះ និងដែលទាក់ទងទៅនឹងវាសនាដ៏អស់កល្បរបស់អ្នក ។

តាំងពីសម័យនៃការស្តារឡើងវិញពីដំបូងៗ បងប្អូនប្រុសៗ ហ្មត់ចត់ខ្លាំងណាស់ចំពោះករណីយកិច្ចរបស់ពួកគាត់ក្នុងការប្រកាសដំណឹងល្អ ។ ក្នុងឆ្នាំ 1837 ដែលមានរយៈពេលតែប្រាំពីរឆ្នាំក្រោយការស្ថាបនាសាសនាចក្រប៉ុណ្ណោះ គឺនៅពេលដែលមានភាពក្រីក្រ និងការលំបាក នោះពួកអ្នកផ្សព្វផ្សាយសាសនាត្រូវបានបញ្ជូនទៅបង្រៀនដំណឹងល្អក្នុងប្រទេសអង់គ្លេស ។ នៅក្នុងពីរបីឆ្នាំបន្ទាប់មកទៀត ពួកអ្នកផ្សព្វផ្សាយសាសនាបានផ្សព្វផ្សាយនៅកន្លែងផ្សេងៗ ដូចជាប្រទេស អូទ្រីស ប្រ៊ែន ប៉ូលីនេស្យា ឥណ្ឌា ចាបាដូស ឈីលី និងប្រទេសចិន ។[15]

ព្រះអម្ចាស់បានប្រទានពរក្នុងកិច្ចការនេះ ហើយសាសនាចក្រកំពុងតែត្រូវបានស្ថាបនាពាសពេញពិភពលោក ។ ការប្រជុំនេះត្រូវបានបកប្រែជា 93 ភាសា ។ យើងមានអំណរគុណចំពោះអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង 52,225 នាក់ ដែលកំពុងបម្រើក្នុងជាង 150 ប្រទេស ។[16] ព្រះអាទិត្យតែងតែរះដើម្បីបំភ្លឺឲ្យពួកអ្នកផ្សព្វផ្សាយសាសនាដ៏សុចរិតដែលកំពុងថ្លែងទីបន្ទាល់ពីព្រះអង្គសង្គ្រោះ ។ សូមគិតពីអំណាចខាងវិញ្ញាណនៃអ្នកផ្សព្វផ្សាយសាសនាជាង 52,000 នាក់ ដោយទទួលព្រះវិញ្ញាណនៃព្រះអម្ចាស់ ប្រកាសដោយក្លាហានថា « ពុំមាននាមណាមួយ ឬផ្លូវ ឬក៏មធ្យោបាយឯទៀតឡើយដែលអាចនាំសេចក្តីសង្គ្រោះមក… មានតែមធ្យោបាយមួយប៉ុណ្ណោះ គឺដោយតាមរយៈព្រះនាមនៃព្រះគ្រីស្ទ » ។[17] យើងសូមបង្ហាញការដឹងគុណចំពោះអ្នកត្រឡប់ពីបេសកកម្មរាប់ពាន់ម៉ឺននាក់ ដែលបានបម្រើ និងបន្តបម្រើដោយអស់ពីកាយចិត្តរបស់គេ ។ ពិភពលោកកំពុងត្រូវបានរៀបចំក្នុងទ្រង់ទ្រាយដ៏ធំ សម្រាប់ការយាងមកជាលើកទីពីរនៃព្រះអង្គសង្គ្រោះ ព្រោះកិច្ចការនៃព្រះអម្ចាស់តាមរយៈអ្នកផ្សព្វផ្សាយសាសនារបស់ទ្រង់ ។

ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាជាកិច្ចការខាងវិញ្ញាណ ។ ភាពសក្តិ-សម និងការរៀបចំ គឺជាការចាំបាច់ ។ ប្រធាន ម៉ុនសុន បានមានប្រសាសន៍ថា « យុវជនទាំងឡាយ ខ្ញុំសូមទូន្មានអ្នកឲ្យរៀបចំខ្លួនដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ រក្សាខ្លួនអ្នកឲ្យបានស្អាតស្អំ និងបរិសុទ្ធ ហើយសក្តិសមដើម្បីធ្វើជាអ្នកតំណាងឲ្យព្រះអម្ចាស់ » ។[18] នៅក្នុងប៉ុន្មានឆ្នាំពីមុនពេលបេសកកម្មរបស់អ្នក សូមចងចាំពីកិច្ចការដ៏ពិសិដ្ឋរបស់អ្នកទុកជាមុន ។ សកម្មភាពរបស់អ្នកមុនពេលបេសកកម្ម នឹងជះឥទ្ធិពលយ៉ាងខ្លាំងចំពោះអំណាចបព្វជិតភាពដែលអ្នកនឹងយកទៅជាមួយក្នុងបេសកកម្ម ។ សូមរៀបចំខ្លួនអ្នកឲ្យបានល្អ ។

ប្រធាន ម៉ុនសុន បានមានប្រសាសន៍ពី « យុវជនគ្រប់គ្នាដែលមានភាពសក្តិសម និងមានសមត្ថភាព [រៀបចំខ្លួន] ដើម្បីបម្រើបេសកកម្ម » ។[19] ក្នុងកាលៈទេសៈ ដូចជាដោយសារបញ្ហាសុខភាព ឬមូលហេតុផ្សេងៗ អ្នកខ្លះមិនអាចបម្រើបេសកកម្មនោះទេ ។ អ្នកនឹងដឹងពីសមត្ថភាពរបស់អ្នកក្នុងការបម្រើ កាលអ្នកនិយាយជាមួយឪពុកម្តាយ និងប៊ីស្សពរបស់អ្នក ។ បើអ្នកស្ថិតក្នុងស្ថានភាពបែបនេះ សូមកុំគិតថាខ្លួនមិនសំខាន់ ក្នុងភារកិច្ចដ៏ឧត្តមនៅពីមុខអ្នកឡើយ ។ ព្រះអម្ចាស់មានព្រះទ័យករុណាចំពោះពួកអ្នកដែលស្រឡាញ់ទ្រង់ ហើយទ្រង់នឹងបើកទ្វារសម្រាប់អ្នកនោះវិញ ។

អ្នកខ្លះអាចឆ្ងល់បើសិនជាពួកគេចាស់ពេកដើម្បីបម្រើ ។ មិត្តម្នាក់របស់ខ្ញុំមកពីប្រទេសចិន បានរកឃើញសាសនាចក្រកាលកំពុងនៅក្នុងប្រទេសកម្ពុជា ពេលគាត់មានអាយុប្រមាណជាពាក់កណ្តាល 20 ឆ្នាំ ។ គាត់បានឆ្ងល់បើគាត់គួរតែនៅគិតពីការចេញបេសកកម្ម ។ បន្ទាប់ពីការអធិស្ឋាន និងនិយាយជាមួយប៊ីស្សពរបស់គាត់ គាត់ត្រូវបានហៅ និងបានបម្រើដោយកិត្តិយសនៅទីក្រុង នូយោក ។ បើអ្នកមានកង្វល់ពីអាយុរបស់អ្នក សូមអធិស្ឋាន និងនិយាយជាមួយប៊ីស្សពរបស់អ្នក ។ គាត់នឹងណែនាំអ្នក ។

50 ភាគរយ នៃអ្នកផ្សព្វផ្សាយសាសនា បម្រើនៅក្នុងស្រុកកំណើតរបស់ខ្លួន ។ នោះជាការណ៍ត្រឹមត្រូវណាស់ ។ ព្រះអម្ចាស់បានសន្យាថា « មនុស្សគ្រប់រូបនឹងបានឮភាពពោរពេញនៃដំណឹងល្អ ដោយនូវពាក្យសម្តីរបស់ខ្លួន និងដោយនូវភាសារបស់ខ្លួន » ។[20] អ្នកនឹងត្រូវបានហៅដោយការព្យាករណ៍ និងបម្រើនៅកន្លែងត្រូវការអ្នកបំផុត ។

ខ្ញុំចូលចិត្តជួបអ្នកផ្សព្វផ្សាយសាសនាជុំវិញពិភពលោក ។ ថ្មីៗនេះ ពេលធ្វើទស្សនកិច្ចទៅកាន់បេសកកម្ម អូស្ត្រាលី ស៊ីដនី អ្នកដឹងទេថាខ្ញុំបានជួបនរណា ? អែលឌើរ ស៊ីដនី ហ្គូអ៊ីង ---វីរបុរសបាល់អោបរបស់ប្រទេស នូហ្សីឡិន ។ ឥឡូវនេះមានអាយុ 67 ឆ្នាំហើយ ហើយជាអ្នកផ្សព្វផ្សាយសាសនាម្តងទៀត ប៉ុន្តែម្តងនេះជាមួយនឹងដៃគូដែលគាត់ជ្រើសរើសផ្ទាល់ខ្លួនគឺ ៖ ស៊ីស្ទើរ ខូលីន ហ្គូអ៊ីង ។ គាត់បានប្រាប់ខ្ញុំពីគ្រួសារមួយដែលពួកគាត់បានបង្រៀន ។ ឪពុកម្តាយជាសមាជិក ប៉ុន្តែមិនសូវសកម្មក្នុងសាសនាចក្រអស់ជាច្រើនឆ្នាំមកហើយ ។ អែលឌើរ និងស៊ីស្ទើរ ហ្គូអ៊ីង បានជួយបញ្ចេះជំនឿរបស់គ្រួសារនោះឡើងវិញ ។ អែលឌើរ ហ្គូអ៊ីង បានប្រាប់ខ្ញុំពីអំណាចដែលគាត់បានទទួលអារម្មណ៍ កាលគាត់បានឈរនៅជិតអាងជ្រមុជទឹក ជិតឪពុកនៃគ្រួសារនោះ កាលដែលកូនប្រុសច្បងរបស់គាត់ ដែលឥឡូវនេះជាអ្នកកាន់បព្វជិតភាព ហើយបានជ្រមុជទឹកឲ្យប្អូនប្រុសស្រីរបស់គេ ។ គាត់បានបង្ហាញពីក្តីអំណរក្នុងការធ្វើជាសាក្សីនៃគ្រួសារដែលមានសាមគ្គីភាព ដែលតាមរកជីវិតអស់កល្បជាមួយគ្នា ។[21]

គណៈប្រធានទីមួយ មានប្រសាសន៍ទៅកាន់អ្នកថា ៖ « អ្នករាល់គ្នាគឺជារិញ្ញាណដែលត្រូវបានជ្រើសរើស ដែលបានកើតមកនៅសព្វថ្ងៃនេះ ជាគ្រាដែលមានការទទួលខុសត្រូវ និងឱកាសព្រមទាំងសេចក្តីល្បួងធំក្រៃលែង... ។ យើងសូមអធិស្ឋានឲ្យអ្នករាល់គ្នា... [ដើម្បី] អ្នកអាចធ្វើកិច្ចការដ៏អស្ចារ្យបានដែលមាននៅចំពោះមុខអ្នករាល់គ្នា...ថាអ្នករាល់គ្នានឹងមានភាពសក្តិសម [និងមានឆន្ទៈ] ដើម្បីបន្តទទួលខុសត្រូវ ក្នុងការស្ថាបនានគរនៃព្រះ និងនៃការរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ » ។[22]

ខ្ញុំស្រឡាញ់គំនូររបស់ ហារី អាន់ឌើរសិន ពីការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ វារំឭកខ្ញុំថាទ្រង់នឹងយាងមកដោយឫទ្ធានុភាព និងអំណាច ។ ព្រឹត្តិការណ៍អស្ចារ្យទាំងឡាយនឹងកើតឡើងលើផែនដី និងនៅក្នុងអាកាស ។[23]

ពួកអ្នកដែលកំពុងរង់ចាំការយាងមករបស់ព្រះអង្គសង្គ្រោះនឹង « សម្លឹងរកមើល [ទ្រង់] » ។ ហើយទ្រង់បានសន្យាថា « យើងនឹងយាងមក ! » ពួកសុចរិតនឹងឃើញទ្រង់ « លើពពក នៅលើមេឃ [ជាមួយនឹងពួកទេវតាដ៏បរិសុទ្ធ] បំពាក់ដោយព្រះចេស្តា និងសិរិល្អជាខ្លាំង » ។24 « ទេវតាមួយទៀតនឹងបន្លឺត្រែរបស់លោក...ហើយពួកបរិសុទ្ធ [ចេញមកពីទិសទាំងបួននៃផែនដី 25]...[នឹង] លើកឡើងទៅជួបទ្រង់ » ។26 ពួកអ្នក « ដែលបានដេកលក់ » មានន័យថាពួកបរិសុទ្ធដែលសក្តិសមដែលបានស្លាប់ទៅហើយនេះ « នឹងចេញមកជួយ [ទ្រង់] [ផងដែរ] » ។[27]

ព្រះគម្ពីរបង្រៀនថា ៖ « ព្រះអម្ចាស់ [នឹង] ដាក់ព្រះបាទទ្រង់ជាន់លើ [ភ្នំ] »28 ហើយ « [ទ្រង់] នឹងបន្លឺសម្លេងរបស់ទ្រង់ ហើយអស់ទាំងចុងផែនដីនឹងបានឮ » ។[29]

ប្អូនប្រុសវ័យក្មេងអ្នកកាន់បព្វជិតភាពរបស់ខ្ញុំអើយ ខ្ញុំថ្លែងទីបន្ទាល់ពីឫទ្ធានុភាពរបស់ទ្រង់ ប៉ុន្តែ សំខាន់បំផុតនោះ គឺពីភាពពិតនៃព្រឹត្តិការណ៍ដ៏រុងរឿងនេះ ។ ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ។ ទ្រង់នឹងត្រឡប់មកផែនដីម្តងទៀត ។ ហើយទោះជានៅឯវាំងននចំហៀងខាងនេះ ឬខាងនោះក្តី អ្នក និងខ្ញុំនឹងត្រៀមអរចំពោះការយាងមករបស់ទ្រង់ ហើយអរព្រះគុណព្រះអម្ចាស់ ដែលទ្រង់បានបញ្ជូនយើងមកផែនដីនៅពេលនេះ ដើម្បីបំពេញនូវភារកិច្ចដ៏ពិសិដ្ឋរបស់យើង ក្នុងការជួយរៀបចំពិភពលោកសម្រាប់ការត្រឡប់មករបស់ទ្រង់ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. Thomas S. Monson « The Lord Needs Missionaries » *Ensign* និង *លីអាហូណា* ខែ មករា ឆ្នាំ 2011 ។
2. Thomas S. Monson « As We Meet Together Again » *Ensign* និង *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2010 ។
3. « New Zealand national rugby union team » Wikipedia.com
4. Bob Howitt « Super Sid: The story of a great All Black» Auckland: New Zealand, Rugby Press Ltd ឆ្នាំ 1978 ។
5. ការសន្ទនាតាមទូរស័ព្ទជាមួយប្រធាន Maxwell Horsford, ស្តេក Kaikohe New Zealand ខែ មិនា ឆ្នាំ 2011 ។
6. ការសន្ទនាតាមទូរស័ព្ទជាមួយ Elder Sidney Going, ខែ មិនា ឆ្នាំ 2011 ។
7. ការឆ្លើយឆ្លងតាមអ៊ីមែលពី Elder Sidney Going, ខែ មិនា ឆ្នាំ 2011 ។
8. « Sid Going » Wikipedia.com
9. ការសន្ទនាតាមទូរស័ព្ទជាមួយ ប្រធាន Maxwell Horsford ដែលជាប្រធានស្តេក Kaikohe New Zealand ខែ មិនា ឆ្នាំ 2011 ។
10. ស៊ីដ ហ្គូអ៊ីងត្រូវបានទទួលរង្វាន់ M.B.E. (Member of the Order of the British Empire) ក្នុងឆ្នាំ 1978 ចំពោះការចូលរួមចំណែករបស់គាត់នៅក្នុងវិស័យកីឡាបាល់ឱប ។ (« Sid Going » Wikipedia.com)
11. ម៉ូសេ 7:62 ។
12. ដានីយ៉ែល 2:45 ។
13. សូមមើល នីហ្វៃទី1 14:12–14 ។
14. គោលលទ្ធិ និងសេចក្តីសញ្ញា 29:7 ។
15. *2011 Church Almanac*, Deseret News ។
16. ថ្ងៃទី 1 ខែ មករា ឆ្នាំ 2011 ។
17. ម៉ូសាយ 3:17 ។
18. Thomas S. Monson « The Lord Needs Missionaries » *Ensign* និង *លីអាហូណា* ខែ មករា ឆ្នាំ 2011 ។

19. Thomas S. Monson, « As We Meet Together Again » *Ensign* និង *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2010 ។

20. គោលលទ្ធិ និងសេចក្តីសញ្ញា 90:11 ។

21. ការសន្ទនាតាមទូរស័ព្ទជាមួយ អែលឌើរ Sidney Going ខែ មិនា ឆ្នាំ 2011 ។

22. « សារលិខិតពីគណៈប្រធានទីមួយ » *ដើម្បីកម្លាំងនៃយុវវ័យ ៖ ការបំពេញកាតព្វកិច្ចរបស់យើងចំពោះព្រះ* ឆ្នាំ 2001 ទំព័រ 2—3 ។

23. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា 45:40; 43:18 ។

24. គោលលទ្ធិ និងសេចក្តីសញ្ញា 45:44 ។

25. គោលលទ្ធិ និងសេចក្តីសញ្ញា 45:46 ។

26. គោលលទ្ធិ និងសេចក្តីសញ្ញា 88:94, 96 ។

27. គោលលទ្ធិ និងសេចក្តីសញ្ញា 45:45 សូមមើលផងដែរ 29:13, 88:96–97 ។

28. គោលលទ្ធិ និងសេចក្តីសញ្ញា 45:48 ។

29. គោលលទ្ធិ និងសេចក្តីសញ្ញា 45:49 ។